# សន្លឹកព័ត៌មាន ស្នងការប្រឆាំងនឹងទាសភាពនៃរដ្ឋ NSW

## តើស្នងការប្រឆាំងនឹងទាសភាពនៃរដ្ឋ NSW ជានរណា?

ស្នងការប្រឆាំងនឹងទាសភាពនៃរដ្ឋ New South Wales គឺបណ្ឌិត James Cockayne។ រយៈពេលកាន់តំណែងប្រាំឆ្នាំរបស់បណ្ឌិត Cockayne បានចាប់ផ្តើម នៅថ្ងៃទី 1 ខែសីហា ឆ្នាំ 2022។

តួនាទីរបស់ស្នងការប្រឆាំងនឹងទាសភាពត្រូវបានបង្កើតឡើងដោយ *ច្បាប់ទាសភាពសម័យទំនើបឆ្នាំ 2018* (រដ្ឋ NSW)។ វាផ្តល់ឱ្យស្នងការនូវមុខងារនានា៖

- ធ្វើការតស៊ូមតិ និងផ្សព្វផ្សាយសកម្មភាពប្រយុទ្ធទល់នឹងទាសភាពសម័យទំនើប
- ធ្វើការកំណត់ និងផ្តល់ជំនួយ និងការគាំទ្រដល់ជនរងគ្រោះនៃទាសភាពសម័យទំនើប
- ធ្វើការធានាច្បាប់ និងគោលនយោបាយនានារបស់រដ្ឋាភិបាលដើម្បីប្រយុទ្ធទល់នឹង ទាសភាពសម័យទំនើបមានប្រសិទ្ធភាព
- គាំទ្រដល់ និងមើលខុសត្រូវលើកិច្ចប្រឹងប្រែងក្នុងការដាក់ដេញថ្លៃសាធារណៈនៅ NSW ដើម្បីដកចេញនូវ ផលិតផលនានាដែលបានមកពីទាសភាពសម័យទំនើបចេញពី ខ្សែសង្វាក់ផ្គត់ផ្គង់។
- ធ្វើការចេញក្រមប្រតិបត្តិ និងរក្សាបញ្ជិកាសាធារណៈទាក់ទងនឹងកិច្ចប្រឹងប្រែងដើម្បីដោះស្រាយហានិភ័យនៃ ទាសភាពសម័យទំនើបនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់
- ធ្វើការលើកកម្ពស់ការយល់ដឹងអំពីទាសភាពសម័យទំនើប។

Office of the
NSW Anti-slavery
Commissioner

Working together
for real freedom

NSW Anti-slavery Commissioner's
Strategic Plan 2023–2026

## តើអ្វីជាទាសភាពសម័យទំនើប?

ទាសភាពសម័យទំនើបកើតឡើងនៅពេលមនុស្សម្នាក់ប្រព្រឹត្តិលើមនុស្សម្នាក់ផ្សេងទៀត ហាក់ដូចជាពួកគេធ្វើជាម្ចាស់លើពួកគេ – ការរឹតបន្តឹងសេរីភាពរបស់ពួកគេ។ ទាសភាពសម័យទំនើបគឺវាក្យស័ព្ទមួយដែលគ្របដណ្តប់លើបទល្មើសផ្នែកច្បាប់ខុសៗគ្នាជាច្រើន។ ទាំងនេះរួមមាន៖

- ទាសភាព
- ស្ថានភាពជាទាសភាព
- ស្ថានភាពជាទាសភាពផ្លូវភេទ
- ពលកម្មដោយបង្ខំ
- អាពាហ៍ពពាហ៍ដោយបង្ខំ
- ទាសភាពបំណុល
- ការជួញដូរមនុស្ស
- ការជ្រើសរើសបុគ្គលិកបោកប្រាស់សម្រាប់ពលកម្ម ឬសេវាកម្មនានា
- ការជួញដូរសរីរាង្គ និងជាលិកា
- ការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមអនឡាញ

## តើមានទាសភាពសម័យទំនើបនៅរដ្ឋ NSW ទេ?

បាទ/ចាស។ មានមនុស្ស 50 លាននាក់ដែលបានប៉ាន់ស្មានថា កំពុងរស់នៅក្នុងទាសភាពសម័យទំនើប នៅទូទាំងពិភពលោក។ មានមនុស្ស 41,000 នាក់ដែលបានប៉ាន់ស្មានថាកំពុងរស់នៅក្នុង ទាសភាពសម័យទំនើបនៅក្នុងប្រទេសអូស្ត្រាលី ដោយមានមនុស្ស 16,400 នាក់ដែលបានប៉ាន់ស្មាន មាននៅក្នុងរដ្ឋញូវសៅវែល (New South Wales)។

## តើឧទាហរណ៍មួយចំនួនអំពីទាសភាពសម័យទំនើបនៅក្នុងរដ្ឋ NSW មានអ្វីខ្លះ?

ការិយាល័យ នៃស្នងការប្រឆាំងនឹងទាសភាព បានទទួលរបាយការណ៍គួរឱ្យទុកចិត្តនៃ ប្រភេទខុសៗគ្នានៃទាសភាពសម័យទំនើបនៅក្នុងរដ្ឋ NSW រួមមាន៖

- កម្មករដែលជាប់អន្ទាក់ក្នុងពលកម្មដោយបង្ខំនៅចំការនៅតាមតំបន់នៃរដ្ឋ NSW។
- កម្មករដែលបានត្រូវបង្ខំឱ្យចូលក្នុងស្ថានភាពជាទាសភាពតាមផ្ទះក្នុងក្រុង។
- ស្ត្រី និងកុមារដែលត្រូវបានរៀបចំខ្លួន និងបង្ខិតបង្ខំឱ្យចូលក្នុងការកេងប្រវ័ញ្ចផ្លូវភេទ តាមការជួបមុខផ្ទាល់ និងតាមផ្ទេតហ្វមប្រព័ន្ធផ្សព្វផ្សាយសង្គម។
- អ្នកសម្អាត និងអ្នកយាមសន្តិសុខដែលធ្វើការនៅក្នុងប្លុកការិយាល័យ បានជាប់ក្នុង ការជាប់ក្នុងទាសភាពបំណុល។
- បុរស ស្ត្រីវ័យក្មេង និងកុមារីដែលត្រូវបានបង្ខំឱ្យរៀបការនៅទីនេះ ឬនៅបរទេស។
- មនុស្សដែលរស់នៅមានពិការភាព ដែលកំពុងត្រូវបានកេងប្រវ័ញ្ចនៅក្នុងកន្លែងធ្វើការ ដាច់ដោយឡែកពីគេ ឬក្នុងកន្លែងថែទាំតាមស្ថាប័ន។
- ពលកម្មដោយបង្ខំ និងពលកម្មកុមារដោយបង្ខំនៃមនុស្សដែលជាមនុស្សជាតិដំបូង (First Nations)។

# សន្លឹកព័ត៌មាន ស្នងការប្រឆាំងនឹងទាសភាពនៃរដ្ឋ NSW

## តើស្នងការប្រឆាំងនឹងទាសភាពកំពុងធ្វើអ្វីខ្លះដើម្បីបញ្ចប់ទាសភាពទំនើបនៅក្នុងរដ្ឋ NSW?

ស្នងការប្រឆាំងនឹងទាសភាពកំពុង៖

**កសាងសមត្ថភាពក្នុងការទប់ស្កាត់** –ធ្វើការជាមួយរដ្ឋាភិបាលរដ្ឋ NSW និងអង្គការមិនមែន រដ្ឋាភិបាលដើម្បី ជួយពួកគេកំណត់អត្តសញ្ញាណមនុស្សដែលងាយរងគ្រោះដោយសារទាសភាពសម័យទំនើប និងទប់ស្កាត់ទង្វើធ្វើឱ្យអ្នកណាម្នាក់រងគ្រោះ។ ការនេះទាក់ទងនឹងកម្មករធ្វើការនៅជួរមុខ និង បង្កើតការគាំទ្រប្រកបដោយសប្រសិទ្ធភាព និងខ្សែទូរសព្ទបន្ទាន់ក្នុងការបញ្ជូនបន្ត។

**ការបើកអនុញ្ញាតឱ្យមានសំណង** –ធ្វើការជាមួយអ្នកផ្តល់សេវាកម្មដើម្បីកែលម្អដល់ការទទួលបានសំណង ប្រកបដោយប្រសិទ្ធភាព សម្រាប់មនុស្សដែលមានបទពិសោធន៍រស់នៅក្នុងទាសភាពសម័យទំនើប។ នេះរួមមានការពង្រឹងការទទួលបានការគាំទ្រប្រកបដោយប្រសិទ្ធភាព និងពង្រឹងភាពជាអ្នកដឹកនាំដល់អ្នកដែលរស់រានមានជីវិត។

**ការពង្រឹងការអនុវត្តអាជីវកម្មប្រកបដោយការទទួលខុសត្រូវ** –ធ្វើការជាមួយរដ្ឋាភិបាល និងក្រុមហ៊ុនឯកជននានា ដើម្បីបង្ហាញភាពជាអ្នកដឹកនាំក្នុងការកំណត់ និងដោះស្រាយ ទាសភាពសម័យទំនើបនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ និងការវិនិយោគ។ ការនេះរួមមានការដកចេញ ផលិតផលនៃទាសភាពសម័យទំនើបចេញពីការដេញថ្លៃជាសាធារណៈ និងការពង្រឹងការអនុវត្ត អាជីវកម្ម ប្រកបដោយការទទួលខុសត្រូវនៅក្នុងផ្នែកឯកជន។

**ការផ្លាស់ប្តូរការរៀបរាប់** –លើកកម្ពស់ការយល់ដឹងអំពីទាសភាពសម័យទំនើបនៅទូទាំងរដ្ឋ NSW តាមរបៀបមួយដែលផ្តល់សិទ្ធិអំណាចដល់អ្នករស់រានមានជីវិត និងបង្កើតករណីអាជីវកម្ម និងករណីគោលនយោបាយសម្រាប់ការប្រឆាំងទល់នឹងទាសភាព។

**ការបង្កើតសហគមន៍គោលបំណង** –ការៀបចំមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តប្រកបដោយចីរភាព និងមានបរិយាប័ន្ននៃ *ច្បាប់ទាសភាពសម័យទំនើបឆ្នាំ 2018* (រដ្ឋ NSW), ការនាំភាគីពាក់ព័ន្ធ មកធ្វើការជាមួយគ្នាឆ្ពោះទៅគោលដៅរបស់ច្បាប់នេះ និងធានាថាកិច្ចប្រឹងប្រែងដើម្បីប្រយុទ្ធ ទលនឹងទាសភាពសម័យទំនើបអាចមានចីរភាព និងបានជោគជ័យ។



## តើអ្នក ឬអ្នកណាម្នាក់ដែលអ្នកស្គាល់ប្រឈមនឹងហានិភ័យទេ?

ប្រសិនបើអ្នក ឬអ្នកណាម្នាក់ដែលអ្នកស្គាល់ស្ថិតនៅក្នុង ឬប្រឈមនឹងហានិភ័យនៃការជួញដូរមនុស្ស ឬទាសភាព អ្នកអាចទាក់ទង៖

- ការិយាល័យស្នងការប្រឆាំងនឹងទាសភាពនៃរដ្ឋ NSWតាម antislavery@justice.nsw.gov.au។ យើងនឹងជួយណែនាំអ្នកទៅសេវាកម្មសុវត្ថិភាព និងសេវាកម្មគាំទ្រនានាដែលអ្នកត្រូវការដូចជាកន្លែងស្នាក់នៅ ដំបូន្មានផ្លូវច្បាប់ និងដំបូន្មានអន្តោប្រវេសន៍ ការពិគ្រោះយោបល់ និងការគាំទ្រផ្នែកហិរញ្ញវត្ថុ។ ស្នងការប្រឆាំងនឹងទាសភាពមិនត្រូវការបញ្ជូនព័ត៌មានរាយការណ៍ដែលបានចែករំលែកជា មួយគាត់ទេ លុះត្រាតែមានមូលដ្ឋានសមហេតុផលដោយសង្ស័យថាកុមារ ឬមនុស្សវ័យក្មេង ប្រឈមនឹងហានិភ័យនៃ គ្រោះថ្នាក់ខ្លាំង ឬ
- ប៉ូលិសសហព័ន្ធអូស្ត្រាលី (AFP) តាមលេខ 131 237 (131AFP) ឬទៅកាន់គេហទំព័ររបស់ AFP នៅឯ www.afp.gov.au សម្រាប់ជំនួយ។

## តើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ទេ?

ការបកប្រែផ្ទាល់មាត់ដោយឥតគិតថ្លៃ មានលក្ខណៈសម្ងាត់អាចរកបានតាមសេវាបកប្រែសរសេរ និងបកប្រែផ្ទាល់មាត់ (Translating & Interpreting Service)តាមលេខ 131 450។ អ្នកបកប្រែផ្ទាល់មាត់ ពី TIS អាចជួយអ្នកធ្វើទំនាក់ទំនងជាមួយសេវាកម្មដទៃទៀត។ យ៉ាងណាក៏ដោយ TIS មិនផ្តល់ការពិគ្រោះយោបល់ទេ។ ការហៅទូរសព្ទទាំងអស់គឺឥតគិតថ្លៃ និងមានលក្ខណៈសម្ងាត់។

## បន្តរក្សាទំនាក់ទំនងជាមួយការិយាល័យស្នងការប្រឆាំងនឹងទាសភាពសម័យទំនើបនៃរដ្ឋ NSW

**ចូលមើលគេហទំព័ររបស់យើង**

**Website:** dcjnsw.info/antislaverycommissioner

**Facebook:** @Office of the NSW Anti-slavery Commissioner

**LinkedIn:** @Office of the NSW Anti-slavery Commissioner